# សិក្ខាសាលាពិគ្រោះយោបល់
# លើគម្រោង NAMA ប្រសិទ្ធិភាពថាមពលនៅក្នុងវិស័យឧស្សាហកម្ម
# កាត់ដេរកម្ពុជានៃព្រះរាជាណាចក្រកម្ពុជា និងក្នុងវិស័យថាមពលកកើតឡើងវិញ
# នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ

នាព្រឹកថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៥ នៅសណ្ឋាគារ HIMAWARI នាយកដ្ឋានបច្ចេកទេស វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម សហការជាមួយ UNDP(United Nations Development Programme) បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់លើគម្រោង **NAMA** (Nationally Appropriate Mitigation Actions) ស្តីពី **"ប្រសិទ្ធិភាពថាមពលនៅក្នុងវិស័យឧស្សាហកម្ម កាត់ដេរកម្ពុជានៃព្រះរាជាណាចក្រកម្ពុជា និងក្នុងវិស័យថាមពលកកើតឡើងវិញនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ"** ក្រោមអធិបតីភាព **ឯកឧត្តមបណ្ឌិត ទឹង ស៊ីនី** អនុរដ្ឋលេខាធិការក្រសួងឧស្សាហកម្ម និងសិប្បកម្ម (តំណាង **ឯកឧត្តម សាត សាមី** រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម និងសិប្បកម្ម)។ កិច្ចពិភាក្សាក្នុងសិក្ខាសាលានេះត្រូវបានដឹកនាំ និងសម្របសម្រួលដោយ **ឯកឧត្តម សឹម ណារ៉ា** អគ្គនាយកឧស្សាហកម្ម និង**លោក វ៉ែន គៀហាក់** ប្រធាននាយកដ្ឋានបច្ចេកទេស វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា និងមានការចូលរួមពីតំណាងក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្រសួងបរិស្ថាន ក្រសួងរ៉ែ និងថាមពល តំណាងធនាគារ ACLEDA សមាគមន៍កាត់ដេរកម្ពុជា(GMAC) ការិយាល័យផលិតកម្មស្អាតជាតិកម្ពុជា(NCPO) និងបណ្តាក្រុមហ៊ុនកាត់ដេរមួយចំនួន ព្រមទាំងតំណាងមកពីក្រសួងរ៉ែ និងថាមពល និងវិទ្យាស្ថានថាមពលកកើតឡើងវិញនៃប្រទេសឡាវសរុបទាំងអស់ ៤៦នាក់។

សិក្ខាសាលានេះរៀបចំឡើងក្នុងគោលបំណងស្វែងរកការគៀងគរផ្នែកថវិកា និងការចូលរួមពីភាគីឯកជន ដៃគូអភិវឌ្ឍ និងក្រសួងពាក់ព័ន្ធសំខាន់ៗចូលក្នុងការកសាងគម្រោង NAMA **"ប្រសិទ្ធិភាពថាមពលនៅក្នុងវិស័យឧស្សាហកម្មកាត់ដេរកម្ពុជា និងក្នុងវិស័យថាមពលករកើតឡើងវិញ នៃប្រទេសឡាវ"** រួមទាំងកំណត់ចំនុចអាទិភាពនៃកិច្ចសហប្រតិបត្តិការរវាងព្រះរាជាណាចក្រកម្ពុជា និងLao PDR។ សិក្ខាសាលាបានបញ្ចប់នៅវេលាម៉ោង ១៤: ០០ នាទី នាថ្ងៃដដែលប្រកបដោយការចូលរួមផ្តល់មតិយោបល់ និងការពិភាក្សាយ៉ាងសកម្មពីសមាជិកនៃអង្គសិក្ខាសាលាទាំងមូល។




Joint Stakeholder Consultation Workshop
on


EXIT
Joint Stakeholder Consultation Workshop
on
the NAMA on Energy Efficiency in the Garment
Industry of Cambodia and the NAMA for the